**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា**

លេខ ២០-០២-2024 **អ.ប.ម.អ.ក**

**របាយការណ៍ប្រចាំ ឆ្នាំ២០២៣**

**គម្រោងដែលអនុវត្តដោយផ្ទាល់**

**របស់ អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា**

**សេចក្តីផ្តើម**

នៅដើមឆ្នាំ២០២៣ **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** បានចាប់ផ្តើមបន្តគម្រោងរបស់ខ្លួននៅក្នុងឆ្នាំសិក្សាថ្មី ដោយបន្តគម្រោងបង្រៀនភាសារអង់គ្លេសរបស់យើងក្នុងឆ្នាំ២០២៣ នេះព្រោះយើងនៅតែមានការគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និង សំភារៈ ពីម្ចាស់ជំនួយនានាទាំងក្នុង និង ក្រៅប្រទេស **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** ដែលជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ដែលទទួលស្គាល់ដោយរាជរដ្ឋាភិបាល តាមរយៈក្រសួងមហាផ្ទៃ បានខិតខំបំពេញការងារលើគម្រោងអប់រំសំរាប់កុមារនៅក្នុងតំបន់គោលដៅរបស់ខ្លួនរហូតទទួលបានលទ្ធផលដ៏ល្អ ដែលអង្គការសូមរាយការណ៍ជូនខាងក្រោមៈ

# ក. កម្មវិធីអប់រំភាសារអង់គ្លេស ដោយឥតគិតថ្លៃ

## ក.១ សេចក្តីផ្តើម

នៅពេលសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងអប់រំ យុវជន និង កីឡា បានចាប់ផ្តើមបើកបវេសនកាល សម្រាប់ឆ្នាំថ្មី **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** ក៏បានចាប់ផ្តើមសកម្មភាពជាថ្មីសម្រាប់ឆ្នាំថ្មីផងដែរ ដើម្បីបន្តជួយបណ្តុះបណ្តាល ភាសា អង់គ្លេស ដល់កុមារាកុមារី សិស្សានុសិស្ស នៅក្នុងសហគមន៍ជារៀងរាល់ថ្ងៃដោយឥតគិតថ្លៃ ដោយមានការជួយឧបត្ថម្ភពីមូលនិធិសប្បុរសធម៌អាយហ៊ើប (IHERB) តាមរយៈអង្គការ CCAFO និងសប្បុរសជននានា នោះ **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** បានបន្តគម្រោងអប់រំផ្នែកភាសាអង់គ្លេសដោយមិនយកកម្រៃ សម្រាប់សិស្សសាលាមកពី សាលាបឋមសិក្សា និងអនុវិទ្យាល័យ ស្ថិតក្នុងឃុំចំនួនបីគឺ ត្រពាំងធំ និង ឃុំកំពង់ភ្លុក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ហើយនិង ឃុំមួយផ្សេងទៀត គឺឃុំខ្វាស់ ស្រុកសូទ្រនិគមន៍ខេត្តសៀមរាប។

អាសយដ្ឋាន ៖ ផ្ទះលេខ.............ផ្លូវជាតិលេខ 6A .ឃុំ ត្រពាំងធំ ស្រុកប្រាសាទ បាគង ខេត្ត សៀមរាប។
ទូរស័ព្ទទំនាក់ទំនង ៖.011 2118008 / 015 218008 Email: pagna.pcef.cambodia@gmail.com

## ក.២ ស្ថិតិគ្រូ និង សិស្ស

នៅដើមខែមករាឆ្នាំ ២០២៣ កម្មវិធីសិក្សាសម្រាប់ឆ្នាំថ្មីបានចាប់ផ្តើម ដោយមានគ្រូសរុបចំនួន៧នាក់ (ស្រី៤នាក់) ដែលកំពុងតែបន្តធ្វើការជាមួយគ្នា ហើយក៏មានគ្រូពីរនាក់ដែលធ្លាប់ជាសិស្សដែលបានរៀនចប់ពី **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** របស់យើងផងដែរ ។

ក្នុងឆ្នាំ២០២៣នេះយើងមានសិស្សសរុបទាំងពីរសាខាចំនួន៧៨៨ នាក់ (សិស្សស្រីចំនួន ៤៧២នាក់) ដែលបានចូលរួមក្នុងគម្រោងអប់រំផ្នែកភាសាអង់គ្លេសរបស់យើង។

សម្រាប់កម្មវិធីឆ្នាំ២០២៣ កម្មវិធីបង្រៀនទាំងអស់ត្រូវបានបន្តទៅលើស្ថានភាពជាក់ស្តែងជាមួយសិស្សជាច្រើនដែលបានចូលរួម។

## ក.៣ ទីតាំងទី១ នៅ ភូមិល្វា ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង ខេត្តសៀមរាប

យើងខ្ញុំបានធ្វើការបែងចែកសិស្សទៅជា ១៤ ថ្នាក់ ហើយសម្រាប់ថ្នាក់ពេលព្រឹកមាន៤ថ្នាក់ ជាមួយការបង្រៀនចាប់ផ្តើមពីម៉ោង 7.30ព្រឹក ដល់ម៉ោង១០.៣០ព្រឹក (មួយថ្នាក់ត្រូវរៀន ១ម៉ោងកន្លះ)។ សំរាប់ថ្នាក់ពេលរសៀលមានចំនួន ៤ថ្នាក់ ហើយមួយថ្នាក់ត្រូវរៀន ១ម៉ោងកន្លះដូចគ្នា ដោយចាប់ពីម៉ោង

១រសៀល ដល់ម៉ោង៤ រសៀល។ សំរាប់ថ្នាក់ពេលយប់មានចំនួន ៦ថ្នាក់ ហើយមួយថ្នាក់ត្រូវរៀន ១ម៉ោង ដោយចាប់ពីម៉ោង ៦យប់ ដល់ម៉ោង៨យប់។

នៅតាំងទី១ ក្នុង ភូមិល្វា ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង ខេត្តសៀមរាប ដើមឆ្នាំ២០២៣យើងមានសិស្សចំនួន ៤៥៥នាក់ (សិស្សស្រីចំនួន ២៦៧ នាក់) ចូលរួមក្នុងគម្រោងអប់រំផ្នែកភាសាអង់គ្លេសរបស់យើង ប៉ុន្តែមកដល់ចុងឆ្នាំ២០២៣ កម្រោងយើងមានសិស្សនៅសល់ត្រឹមតែ ៣៥៣ នាក់ ស្រីចំនួន ២១៤នាក់។

ចំនួនសិស្សដែលបានបញ្ចប់ថ្នាក់មានចំនួន ១៧នាក់ សិស្សស្រីចំនួន ១២នាក់

ចំនួនសិស្សដែរបោះបង់សាលាចំនួន ៨៥នាក់ ស្រី ៥៣នាក់។

អាសយដ្ឋាន ៖ ផ្ទះលេខ.............ផ្លូវជាតិលេខ 6A .ឃុំ ត្រពាំងធំ   ស្រុកប្រាសាទ បាគង ខេត្ត សៀមរាប។
ទូរស័ព្ទទំនាក់ទំនង ៖.011 2118008 / 015 218008  Email: pagna.pcef.cambodia@gmail.com

| ទីតាំងទី១ នៅភូមិល្វា ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង ខេត្តសៀមរាប | | | | | | | |
|---|---|---|---|---|---|---|---|
| ឈ្មោះគ្រូ | កាលវិភាគបង្រៀន | ម៉ោង | នៅសាលារដ្ឋថ្នាក់ទី | កំរិតសៀវភៅដែលត្រូវរៀន | ចំនួនសរុប | ស្រី | អាយុ |
| ឡេង សែរវង្ស | ព្រឹក | 7.30-9.00 | 1+4 | ABC | 32 | 15 | 7 ទៅ 9 ឆ្នាំ |
| | | 9.00-10.30 | 2+4 | ABC | 33 | 14 | 8 ទៅ 10 ឆ្នាំ |
| ជិម ចំរុង | | 7.30-9.00 | 4+6 | Starter | 15 | 10 | 9 ទៅ 11 ឆ្នាំ |
| | | 9.00.10.30 | 6+7 | Starter | 15 | 13 | 10 ទៅ 12 ឆ្នាំ |
| លយ គីមឡាង | ល្ងាច | 1.00-2.30 | 2+4 | ABC | 51 | 32 | 7 ទៅ 9 ឆ្នាំ |
| | | 2.30-4.00 | 4+6 | ABC | 42 | 17 | 8 ទៅ 10 ឆ្នាំ |
| ឡេង សែរវង្ស | ល្ងាច | 1.00-2.00 | 1+3 | Starter | 16 | 8 | 9 ទៅ 11 ឆ្នាំ |
| | | 2.00-3.00 | 2+4 | Starter | 13 | 6 | 10 ទៅ 12 ឆ្នាំ |
| ស៊ិន សុភ័ក្តិ | យប់ | 6.00-7.00 | 7+9 | Family & Friends 1 | 44 | 27 | 12 ទៅ 14 ឆ្នាំ |
| | យប់ | 7.00-8.00 | 7+9 | Family & Friends 2 | 47 | 39 | 13 ទៅ 15 ឆ្នាំ |
| ជិម ចំរុង | យប់ | 6.00-7.00 | 8+10 | Family & Friends 3 | 74 | 47 | 13 ទៅ 16 ឆ្នាំ |
| | | 7.00-8.00 | 11+12 | Family & Friends 4 | 22 | 11 | 14 ទៅ 17 ឆ្នាំ |
| ឡេង សែរវង្ស | យប់ | 6.00-7.00 | 6+8 | Family & Friends 5 | 26 | 18 | 15 ទៅ 18 ឆ្នាំ |
| | | 7.00 -8.00 | 8+10 | Family & Friends 6 | 17 | 12 | 15 ទៅ 19 ឆ្នាំ |
| | | | | សរុបនៅភូមិល្វា | 455 | 267 | |
| | | | | សិស្សបោះបង់សាលា | 85 | 53 | |

អាសយដ្ឋាន ៖ ផ្ទះលេខ............ផ្លូវជាតិលេខ 6A .ឃុំ ត្រពាំងធំ ស្រុកប្រាសាទ បាគង ខេត្ត សៀមរាប។
ទូរស័ព្ទទំនាក់ទំនង ៖.011 2118008 / 015 218008 Email: pagna.pcef.cambodia@gmail.com

## ក.៤ ទីតាំងទី២ នៅភូមិគោកក្ដុល ឃុំកំពង់ភ្លុក ស្រុកប្រាសាទបាគង ខេត្តសៀមរាប

យើងខ្ញុំបានធ្វើការបែងចែកសិស្សជា៩ក្រុម ហើយសម្រាប់ថ្នាក់ពេលព្រឹកមាន៣ថ្នាក់ ជាមួយការបង្រៀនចាប់ផ្ដើមពីម៉ោង ៨.០០ព្រឹក ដល់ម៉ោង១១.០០ព្រឹក (មួយថ្នាក់ត្រូវបង្រៀន ១ម៉ោង)។
សំរាប់ថ្នាក់ពេលរសៀលមានចំនួន ៣ថ្នាក់ ហើយមួយថ្នាក់ត្រូវបង្រៀន ១ម៉ោង ដោយចាប់ពីម៉ោង ១រសៀលដល់ម៉ោង៥ រសៀល។ សំរាប់ថ្នាក់ពេលយប់មានចំនួន ៣ថ្នាក់ ហើយមួយថ្នាក់ត្រូវបង្រៀន ១ម៉ោងផងដេរ ដោយចាប់ពីម៉ោង ៥យប់ ដល់ម៉ោង៨យប់។

នៅតាំងទី២ ក្នុង ភូមិគោកក្ដុល ឃុំកំពង់ភ្លុក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ដើមឆ្នាំ២០២៣យើងមានសិស្សចំនួន ៣៣៣នាក់ (ស្រីចំនួន ២០៥នាក់) បានចូលរួមក្នុងគម្រោងអប់រំផ្នែកភាសាអង់គ្លេសរបស់យើង ប៉ុន្តែមកដល់ចុងឆ្នាំ២០២៣ កម្រោងយើងមានសិស្សនៅសល់ត្រឹមតែ ២៧០នាក់ ស្រីចំនួន ១៦៨នាក់។

ចំនួនសិស្សដែរបោះបង់សាលាចំនួន ៦៣នាក់ ស្រី ៤១នាក់។

| ទីតាំងទី២ នៅភូមិ គោកក្ដុល ឃុំកំពង់ភ្លុក ស្រុកប្រាសាទបាគង ខេត្តសៀមរាប | | | | | | | |
|---|---|---|---|---|---|---|---|
| ឈ្មោះគ្រូ | កាលវិភាគបង្រៀន | ម៉ោង | នៅសាលារដ្ឋថ្នាក់ទី | កំរិតសៀវភៅដែលត្រូវរៀន | ចំនួនសរុប | ស្រី | អាយុ |
| ណូត ស្រីល័ក្ខ | ព្រឹក | 8.00-9.00 | 1+4 | ABC | 33 | 18 | 6 ទៅ 8 ឆ្នាំ |
| ណូត ស្រីល័ក្ខ | | 9.00-10.00 | 3+5 | Starter | 19 | 8 | 8 ទៅ 10 ឆ្នាំ |
| ឡេង សូរិន | | 10.00-11.30 | 6+7 | Family &Friends 1 | 8 | 5 | 10 ទៅ 13 ឆ្នាំ |
| លាង សុនាត | រសៀល | 1.00-2.00 | 1+4 | ABC | 38 | 25 | 6 ទៅ 8 ឆ្នាំ |
| លាង សុនាត | | 2.00-3.30 | 3+5 | Starter | 20 | 12 | 8 ទៅ 10 ឆ្នាំ |
| ឡេង សូរិន | | 3.30-5.00 | 6+7 | Family &Friends 1 | 18 | 11 | 10 ទៅ 13 ឆ្នាំ |
| លាង សុនាត | យប់ | 5.00-6.00 | 8+10 | Family &Friends 2 | 36 | 20 | 13 ទៅ 15 ឆ្នាំ |
| ឡេង សូរិន | យប់ | 6.00-7.00 | 8+10 | Family &Friends 2 | 44 | 35 | 13 ទៅ 15 ឆ្នាំ |
| ឡេង សូរិន | | 7.00-8.00 | 9+11 | Family & Friends 3 | 25 | 16 | 15 ទៅ 17 ឆ្នាំ |
| | | | | សរុបនៅភូមិគោកក្ដុល | 241 | 150 | |
| | | | | សិស្សបោះបង់សាលា | 46 | 21 | |

## ក.៥ សកម្មភាពទូទៅរបស់ អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា

សកម្មភាពបង្រៀនភាសាតាមប្រព័ន្ធព័ត៌មានវិទ្យាត្រូវបានបញ្ចូលក្នុងមេរៀនគ្រប់ថ្នាក់នីមួយៗ ក្នុងគោលបំណងដើម្បីឲ្យសិស្សទាំងអស់បានស្តាប់, ទស្សនាកំរងមេរៀន និងហាត់បញ្ចេញសំលេង ឲ្យបានត្រឹមត្រូវ។

យើងខ្ញុំបានខិតខំទំនាក់ទំនងរកគ្រូបង្រៀនស្ម័គ្គចិត្តជាច្រើនមកពីតាមប្រទេសផ្សេងៗគ្នាដើម្បីជួយបង្រៀននិង ផ្តល់ឱកាសឱ្យសិស្សបានហ្វឹកហាត់អភិវឌ្ឍសមត្ថភាពផ្នែកស្តាប់និងបញ្ចេញសំលេងជាមួយគ្រូបរទេសដោយផ្ទាល់ ផ្ទាល់ផងដែរ។

ក្រុមការងារយើងខ្ញុំនៅតែបន្តយកចិត្តទុកដាក់ទៅលើអនាម័យ មុនពេលចូលរៀន តាមការណែនាំរបស់ក្រសួងអប់រំ និង ក្រសួងសុខាភិបាល ។

លោកគ្រូអ្នកគ្រូបានបង្រៀនសិស្សតាមកាលវិភាគដែលសាលាបានកំណត់ពេលវេលា ទៅតាមម៉ោងសិស្សដែលបាន កំណត់។

ជាពិសេស**អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** យើងខ្ញុំបានចូលរួមរាល់សកម្មភាពជាមួយអាជ្ញាធរដូចជា៖ ការសំអាត ស្ថាន ផ្តល់អំណោយផ្សេងៗ ។ល។

យើងមានការប្រជុំជាមួយបុគ្គលិកជារៀងរាល់ខែ ហើយក៏មានការចូលរួមប្រជុំជាមួយអង្គការសង្គមស៊ីវិល និង អង្គ ភាពផ្សេងៗទៀតផងដែរ។

ម៉្យាងទៀតខាង**អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** របស់យើងក៏មានការហ្វឹកហាត់ (teachers training course) ដើម្បី អភិវឌ្ឍន៍សមត្ថភាពគ្រូបង្គោលអំពីការបង្រៀនសិស្សអោយមានភាពរីកចំរើនផងដែរ។

### ក.៦ លទ្ធផលសំសម្រេចបាន

គម្រោងអប់រំផ្នែកភាសាអង់គ្លេសរបស់ **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** ថ្វីត្បិតតែពួកគេរៀនមិនសូវ បានជិតដល់ដូចកាលឆ្នាំមុនៗ ប៉ុន្តែពួកគេជាង៨០%បានប្រលងជាប់និងបានបន្តទៅថ្នាក់កម្រិតខ្ពស់ជាងមុនគួរ អោយសរសើរ លើសពីនេះទៅទៀតយើងឃើញថាមាតាបិតាសិស្សក៏មានការចូលរួមច្រើនផងដែរ នៅពេលដែរ អង្គការត្រូវការជំនួយពីពួកគាត់ម្តងៗ។

ថ្វីត្បិតតែមានការប្រកាសពីរាជរដ្ឋាភិបាលកម្ពុជា និងក្រសួង សុខាភិបាល ក៏ដូចជា ក្រសួងអប់រំឲ្យពួក យើងបានចូលរៀនវិញជាធម្មតាក៏ដោយ ប៉ុន្តែ **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា**នៅតែបន្តអនុវត្តឲ្យបានខ្ជាប់ខ្ជួន

អំពីការសម្អាត និងធ្វើអនាម័យ ដើម្បីការពារទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ (Covid-19)និងជំងឺផ្សេងៗទៀតផងដែរ យើងខ្ញុំបាននាំគ្នារក្សាអនាម័យយ៉ាងម៉ឺងម៉ាត់បំផុតតាមតែអាចធ្វើទៅបាន។

## ខ. ការចូលរួមប្រជុំនិងវគ្គបណ្តុះបណ្តាល

### ខ.១ គោលបំណង

ដើម្បីស្តាប់យល់ដឹងអំពីច្បាប់និងបញ្ហារមួយជំនួនពីថ្នាក់ដឹកនាំនិងជាកិច្ចសហការដើម្បីជាការរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍ដើម្បីចូលរួមកាត់បន្ថយភាពអវិជ្ជា។

### ខ.២ បេសកកម្ម

**អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** បានចូលរួមប្រជុំនិងវគ្គណ្តុះបណ្តាលដូចជា។

- ប្រជុំជាមួយក្រុមការងាររបស់ខ្លួនពីរដងរៀងរាល់ខែ និងបណ្តុះបណ្តាលបុគ្គលិករបស់ខ្លួនដើម្បីឈានទៅរកភាពរីកចំរើនសមត្ថភាពមួយដងក្នុងមួយខែជាប្រចាំ។
- ប្រជុំសិក្សានុសិស្សដើម្បីយល់ដឹងពីច្បាប់វិន័យរបស់សាលាព្រមទាំងបញ្ជ្រៀតចូលនៅសុជីវធម៌សិលធម៌ និង ភូមិឃុំមានសុវត្ថិភាពផងដែរ។
- **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** ក៏មានការជួបជុំជាមួយអាណាព្យាបាលសិស្សពីរដងក្នុងមួយឆ្នាំដើម្បីពិភាក្សាអំពីភាពរីកចំរើននិងបញ្ហារមួយចំនួនដែលបានកើតឡើងផងដែរ។
- ចូលរួមប្រជុំប្រចាំខែជាមយយក្រុមប្រឹក្សាឃុំជារៀងរាល់ខែ។
- ប្រជុំថ្នាក់ខេត្តជាមួយក្រុមប្រឹក្សាខេត្តពីរដងក្នុងមយយឆ្នាំ និងប្រជុំថ្នាក់ខេត្តជាមួយ វ.ស.ស ពីរដងក្នុងមួយឆ្នាំផងដែរ។
- **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** បានចូលរួមវគ្គបណ្តុះបណ្តាលជាមួយ **ជ.គ.ប** ដើម្បីធ្វើជាអ្នកស្ម័គ្រចិត្តសង្កេតការណ៍បោះឆ្នោត ក្នុងអាណត្តទី៧ ២០២៣ និងបានចូលរួមសង្កេការណ៍ផងដែរ។
- **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** ក៏បានចូលរួមប្រជុំជាច្រើនទៀត ដូចជា ប្រជុំតាមសាលារដ្ឋមយយចំនួនក្នុងតំបន់គោលដៅ និងប្រជុំបណ្តាញអង្គការនិងសមាគម ។ល។

## គ. ជួសជុលនិងសាងសង់

### គ.១ គោលបំណ

ដើម្បីផ្តល់ភាពងាយស្រួលនិងសុវត្ថិភាពដល់សិក្សានុសិស្ស ជាពិសេសដើម្បីអោយសិស្សមានកន្លែងអង្គុយរៀនបានស្រួលបួលផងដេរ។

## គ.២ បេសកកម្ម

**អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** បានចូលរួមប្រជុំនិងវគ្គណ្ដុះបណ្ដាលដូចជា។

- ក្នុងឆ្នាំ២០២៣នេះយើងបានសាងសង់របងខាងមុខសាលាមយយខ្សែមានប្រវែង៣០ម៉ែត្រ កម្ពស់៣ម៉ែត្រសាងពីពិតដ្ឋ។
- ជួសជុលបន្ទប់រៀនមួយបន្ទប់ដែលលិចទឹក និងលាបថ្នាំប្រូពណ៌ខាងក្នុងបន្ទប់ផងដែរ។
- យើងបានក្រាលការ៉ូការូឡានៅទីធ្លាសាលាមុខបន្ទប់រៀនដើម្បីងាយស្រួលដល់សិក្សានុសិស្ស ព្រោះពីមុនរៀងរាល់រដុវវស្សារមានភ្លៀងធ្លាក់តីធ្លាសាលាមានផុកច្រើនបិបាកដើរនិងប្រឡាក់ផុកពេលចូលរៀនផងដែរ។
- នៅចុងឆ្នាំ២០២៣នេះផងដែរ**អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** បានរៃអង្គាសថវិការដើម្បីសាងសង់បន្ទប់រៀនចំនួនបីបន្ទប់បន្ថែមទៀន ប៉ុន្តែដោយថវិការដែលរៃអង្គាសបានមិនគ្រប់ពួកយើងបានសម្រេចសាងសង់បន្តិចម្ដងៗ នៅខែធ្នូ២០២៣យើងចាប់ផ្តើមសាងសង់ដំណាក់កាលទីមួយប្រហែលជា២០%ហើយក៏សម្រេចផ្អាកសិនរង់ចាំរៃអង្គាសបន្តទៀតទើបចាប់ផ្តើមធ្វើបន្ថែម។

# ឃ. បញ្ហាប្រឈម និងដំណោះស្រាយ

### ឃ.១. បញ្ហាប្រឈម

- ខ្វះថវិការសាងសង់បន្ទប់រៀនបន្ថែម និងខ្វះថវិការជយលគ្រូបន្ថែមដោយសារតែមានកំណើនសិស្សកើនឡើងៗជារៀងរាល់ឆ្នាំ ដែលជាហេតុធ្វើអោយយើងខ្វះថ្នាក់រៀន និងខ្វះគ្រូបង្គោលបន្ថែម។
- សមត្ថភាពគ្រូតាមមូលដ្ឋាននៅមានកម្រិត យើងខ្ញុំនៅតែត្រូវការអ្នកឧបត្ថម្ភសម្រាប់ការសិក្សារបស់គ្រូៗបន្ថែមទៀត។

### គ.២. ដំណោះស្រាយ

-យើងខ្ញុំនៅតែស្វែងរកសប្បុរសជនដើម្បីជួយឧបត្ថម្ភថ្លៃសាងសង់បន្ទប់រៀនបន្ថែមក៏ដូចជារកជំនួយឧបត្ថម្ភដើម្បីជួលគ្រូបន្ថែមទៀតផងដែរ។

-អង្គការរបស់យើងខ្ញុំសូមធ្វើការអំពាវនាវដល់បងប្អូនសប្បុរសជន ក្នុងនិងក្រៅប្រទេសមេត្តាជួយឧបត្ថម្ភគាំទ្រដើម្បីអោយគម្រោងយើងខ្ញុំបានបន្តជួយបង្រៀនដល់កុមារក្រីក្រតាមជនបទបន្តទៀត។

-យើងខ្ញុំនៅតែបន្តរកវិធីសាស្ត្រដើម្បីជួយគ្រូៗមូលដ្ឋានអោយមានសមត្ថភាពប្រសើរឡើងតាមតែអាចធ្វើបាន។

**ឃ. សន្និដ្ឋាន**

ទោះបីជាជួបប្រទះនៅបញ្ហាប្រឈមមួយចំនួន  ក៏ដោយក៏គម្រោងអប់រំផ្នែកភាសាអង់គ្លេសរបស់ **អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា** នៅតែមានដំណើរការជាបណ្តើរៗ  ពីមួយថ្ងៃទៅមួយថ្ងៃកំពុងមានសន្ទុះទៅមុខ សំដៅទៅជួយដល់ការអភិវឌ្ឍធនធានមនុស្សជំនាន់ថ្មីរបស់យើងសម្រាប់បន្តវេននាពេលអនាគត  ម្យ៉ាងវិញទៀត នៅពេលយើងសាងសង់បន្ទប់រួចរាល់យើងនិងរកមូលនិធិដើម្បីបើកថ្នាក់កុំព្យូទ័រថ្នាក់មូលដ្ឋានផងដែរ ។

ថ្ងៃអង្គារ ១១ កើត ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

សៀមរាប,ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៤

**ប្រធានអង្គការ**

អាសយដ្ឋាន ៖ ផ្ទះលេខ.............ផ្លូវជាតិលេខ 6A .ឃុំ ត្រពាំងធំ  ស្រុកប្រាសាទ បាគង ខេត្ត សៀមរាប។
ទូរស័ព្ទទំនាក់ទំនង ៖.011 2118008 / 015 218008  Email: pagna.pcef.cambodia@gmail.com